00224746

D25/8/8

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**Declassified to Public**
**06 September 2012**

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០១/១៨-០៧-២០០៧-អវតក-កសចស (អបជ)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២២ កញ្ញា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22/09/2008
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

---

## ការទទួលស្គាល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

កាំង ហ្កេកអ៊ាវ ហៅ "ឌុច"

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត
Silke STUDZINSKY
គឹម ម៉េងឃី
Martine JACQUIN
Philippe CANNONE
ម៉ុច សុវណ្ណារី

**សហមេធាវីការពារក្តី**

ការ សាវុត្ថ
François ROUX

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22/09/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

00224747



D25/8/8

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" កត់សំគាល់ឃើញមានកិច្ចស៊ើបសួរ ដែលធ្វើឡើងចំពោះឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស និងបញ្ជូនសំណុំរឿងនេះទៅអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមវិធានផ្ទៃក្នុង ៦៩(១)។

២. កត់សំគាល់ឃើញថា លោកស្រី **មាសកេត សំភាត់** បានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ (ឯកសារលេខ: D25/8/4) ហើយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ បានតែងតាំងកញ្ញា **ម៉ុច សុវណ្ណារី** ជាមេធាវីកម្ពុជា របស់លោកស្រីបន្ថែមជាមួយ លោក **គីម ម៉េងឃី** និង លោកស្រី Martine JACQUIN ដែលត្រូវបានទទួលស្គាល់ជាសហមេធាវីរបស់លោកស្រី ដែលទទួលបានការយល់ព្រមត្រឹមត្រូវក្នុងបញ្ជីមេធាវី ដែលមានបំណងតំណាងជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ។ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៨ កញ្ញា **ម៉ុច សុវណ្ណារី** បានទទួលនូវការតែងតាំងនេះ។

៣. វិធាន២៣(៧) នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក ចែងថា ៖
"ជនរងគ្រោះដែលចូលរួមក្នុងនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិត្រូវបានតំណាងដោយមេធាវីជាតិ ឬ អន្តរជាតិដោយសហការជាមួយមេធាវីជាតិ [...]"។

៤. សិទ្ធិ និងកាតព្វកិច្ចត្រូវអនុវត្ត ដែលកើតចេញពីការតែងតាំងជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានដាក់ភ្ជាប់ជាមួយនឹងឯកសារនេះ។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច ÷**

ផ្តល់នីតិសម្បទា និងទទួលស្គាល់កញ្ញា **ម៉ុច សុវណ្ណារី** ជាសហមេធាវីបន្ថែមរបស់លោកស្រី **មាសកេត សំភាត់** ក្នុងគោលបំណងនៃកិច្ចស៊ើបសួរ នៅចំពោះមុខ អ.វ.ត.ក ។

ភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

ប្រាក់ គឹមសាន

00224748



# សិទ្ធិ និង ភារកិច្ច របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

- **ការចូលរួមក្នុងកិច្ចការស៊ើបសួររបស់តុលាការ៖** លោក/លោកស្រី ត្រូវបានអនុញ្ញាតឲ្យតំណាងកូនក្ដីរបស់ លោក/លោកស្រី នៅក្នុងកំឡុងពេលដែលពួកគេចូលរួមក្នុងនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.។

- **ការពិនិត្យពិគ្រោះសំណុំរឿង** ៖ លោក/លោកស្រី មានសិទ្ធិពិនិត្យមើល និងថតចម្លងឯកសារពីសំណុំរឿងស៊ើបសួរច្បាប់ដើមណាដែលកូនក្ដីរបស់ លោក/លោកស្រី ជាដើមបណ្ដឹងរដ្ឋប្បវេណីតាមរបៀបថតចម្លងជាក្រដាស ឬ តាមបែបអេឡិចត្រូនិក នៅក្នុងពេលម៉ោងធ្វើការ និងដោយគោរពទៅតាមលក្ខខណ្ឌតម្រូវនៃកិច្ចដំណើរការល្អរបស់ អ.វ.ត.ក។ ការពិនិត្យមើលសំណុំរឿងនេះអាចរៀបចំដោយមានជំនួយរបស់អង្គភាពជនរងគ្រោះ ឬ មន្ត្រីគ្រប់គ្រងសំណុំរឿង ប៉ុន្តែត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីសមត្ថកិច្ច។ លោក/លោកស្រី អាចថតចម្លង ឬ ស្នើសុំច្បាប់ថតចម្លងឯកសារដែលមាននៅក្នុងសំណុំរឿងតាមចំនួនសមរម្យ និង យកឯកសារទាំងនោះទៅពិភាក្សាជាមួយកូនក្ដីរបស់ លោក/លោកស្រី ប៉ុន្តែ លោក/លោកស្រី មិនអាចប្រគល់ឯកសារថតចម្លងទាំងនោះទៅឲ្យកូនក្ដីរបស់ លោក/លោកស្រី ឬ អ្នកដទៃបានឡើយ។

- **ការរក្សាការសម្ងាត់វិជ្ជាជីវៈ និងការសម្ងាត់នៃកិច្ចការតុលាការ** ៖ តាមរយៈការចូលរួមរបស់កូនក្ដីលោក/លោកស្រីក្នុងឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី លោក/លោកស្រី និងកូនក្ដីរបស់លោក/លោកស្រីនឹងអាចពិនិត្យពិគ្រោះព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿង។ ប៉ុន្តែមានតែចៅក្រម និងព្រះរាជអាជ្ញា នៃ អ.វ.ត.ក ប៉ុណ្ណោះ ដែលអាចផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈបាន។ លោក/លោកស្រី ត្រូវចងដោយកាតព្វកិច្ចរក្សាការសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ និងក្រមវិជ្ជាជីវៈរបស់ លោក/លោកស្រី ដោយមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងឡាយ ដែលលោក/លោកស្រីទទួលបានពីការពិនិត្យពិគ្រោះសំណុំរឿងនោះទេ។

- **ការដាក់តំកល់ឯកសារ៖** នៅពេលដែលកូនក្ដីរបស់លោក/លោកស្រីត្រូវបានទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ រាល់ឯកសារផ្លូវការទាំងអស់ ត្រូវដាក់តំកល់តាមរយៈមន្ត្រីគ្រប់គ្រងសំណុំរឿងដូចមានកំណត់នៅក្នុងសេចក្ដីណែនាំអនុវត្តអំពីការដាក់តំកល់ឯកសារ។ លោក/លោកស្រី នឹងទទួលបានការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកអំពីឯកសារ ដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង

D 25/8/8

ហេតុនេះ លោក/លោកស្រី ត្រូវផ្តល់ជូនអាសយដ្ឋានអ៊ីម៉ែលរបស់លោក/លោកស្រី ឲ្យទៅក្រឡាបញ្ជី នៃការិយាល័យក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ សម្រាប់ប្រើក្នុងការទំនាក់ទំនង។ ការផ្តល់ជូនឯកសារជាក្រដាសអាចធ្វើបានតែក្នុងករណីណា ដែលលោក/លោកស្រី មិនអាចមើលអ៊ីម៉ែលបានប៉ុណ្ណោះ។

វិធាន និងសេចក្តីណែនាំអនុវត្ត ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចពិនិត្យពិគ្រោះ និងថតចម្លងបានតាមរយៈគេហទំព័ររបស់អង្គភាពជនរងគ្រោះ (http://www.eccc.gov.kh/)។ ប្រសិនបើ លោក/លោកស្រី ត្រូវការការណែនាំបន្ថែមទាក់ទិននឹងការធ្វើជាតំណាងកូនក្តីរបស់ លោក/លោកស្រី នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក សូមធ្វើទំនាក់ទំនងជាមួយនឹងអង្គភាពជនរងគ្រោះ។ ✓

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. CHAMBRE PRÉLIMINAIRE

00224750

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

D25/8/8

**INTEROFFICE MEMORANDUM**
**Confidential**

TO: **Anne-Marie Burns**
**Greffier of the Pre-Trial Chamber**

Date: 19 September 2008

Ref: VU-2008-028-Conf

THROUGH:

FROM: Gabriela Gonzalez Rivas, Deputy head of the Victims Unit

SUBJECT: Confirmation of lawyer's admission to the list of lawyers of the Victims Unit

1. The Victims Unit in its capacity as the central contact point between the ECCC and victims and their legal representatives, has been informed that a new Power of Attorney letter from Civil Party Ms. MEASKETH Samphotre (08-VU-00819) was submitted to the Pre-Trial Chamber.

2. In her letter, the Civil Party designate Ms. MOCH Sovannary as her second Cambodian Co-Lawyer, in addition to Mr. KIM Mengkhy. The designated Co-Lawyer is registered in the list of lawyers for victims managed by the Victims Unit and is a member of the Bar Association of the Kingdom of Cambodia, thus entitled to appear before the ECCC.